# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ តុលាការខ្មែរត្រូវមតិជាតិនិងអន្តរជាតិចោទថា ជាតុលាការពុំមានឯករាជ្យ និងពុំមានយុត្តិធម៌ ។

www.hoksavann,com

ថ្ងៃទី១២ កញ្ញា ២០១០



ការចោទថា តុលាការខ្មែរពុំមានឯករាជ្យនិងពុំមានយុត្តិធម៌នោះ ដោយគេសង្កេតឃើញការវិវាទដីធ្លីរវាងប្រជាពលរដ្ឋជាមួយអ្នកមានអំណាច ប្រជាពលរដ្ឋតែងតែចាញ់ រហូតជាប់ពន្ធនាគារ មិនដឹងជាហេតុអ្វី ខ្លះថាមកអំពីប្រជាពលរដ្ឋគ្មានប្រាក់សូកតុលាការ ខ្លះថាតុលាការមិនហ៊ានកាត់ឲ្យអ្នកមានអំណាចចាញ់ទេ ព្រោះភ័យខ្លាចសន្តិសុខផ្ទាល់ខ្លួន ។ ចំពោះភាពមិនឯករាជ្យនៃតុលាការវិញ គេសង្កេតឃើញរាជរដ្ឋាភិបាលមានវិវាទជាមួយគណបក្សប្រឆាំង រាជរដ្ឋាភិបាលតែងមានប្រៀបជានិច្ច ហើយគណបក្សប្រឆាំងតែងតែចាញ់ មានបង់ផាកពិន័យរហូតជាប់ពន្ធនាគារ ។ ក្រៅពីនោះ តុលាការបានកាត់ឲ្យអ្នកសារពត៌មានបង់ផាកពិន័យរហូតជាប់ពន្ធនាគារជាច្រើននាក់ តាមបណ្តឹងរបស់រាជរដ្ឋាភិបាល ដោយចោទពីបទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយពត៌មានមិនពិតជាដើម ។

ប្រទេសណាក៏ដោយ បើតុលាការមិនមានយុត្តិធម៌និងឯករាជ្យហើយ គេចាត់ទុកប្រទេសមិនមានសន្តិសុខឡើយ ព្រោះអ្នកដែលត្រូវចាញ់ទៅជាឈ្នះ អ្នកដែលត្រូវឈ្នះទៅជាចាញ់វិញ ធ្វើឲ្យអ្នកដែលទទួលអយុត្តិធម៌កើតចិត្តក្តៅក្រហាយ អាចកើតអំពើហឹង្សាក្រៅប្រព័ន្ធតុលាការ ព្រោះយល់ថា បើចូលតុលាការក៏គ្មានបានការអ្វីឡើយ ត្រូវតែចាត់ការក្រៅច្បាប់ ព្រោះតុលាការពុំគោរពច្បាប់ដូចគ្នា ។

ប្រទេសដែលកាន់របបប្រជាធិបតេយ្យ គេតែងចែកអំណាចទាំងបី គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការដាច់ពីគ្នា ។ ការទាស់ទែងខ្វែងគំនិតគ្នាក្នុងសង្គមមនុស្សជាការធម្មតា ប៉ុន្តែសំខាន់នៅត្រង់តុលាការកាត់សេចក្តីឲ្យមានយុត្តិធម៌ ទើបធ្វើឲ្យការវិវាទទាំងឡាយស្ងប់រម្ងាប់ទៅវិញ ព្រោះឲ្យតម្លៃដល់អ្នកដែលត្រឹមត្រូវ ផ្តន្ទាទោសដល់អ្នកប្រព្រឹត្តខុស ដែលអ្នកឈ្នះនិងអ្នកចាញ់អាចទទួលយកបានតាមលក្ខណៈច្បាប់ ។ ប្រទេសកម្ពុជាសព្វថ្ងៃ គេសង្កេតឃើញថា តុលាការខ្មែរហាក់ដូចជានៅក្រោមអំណាចនីតិប្រតិបត្តិ គឺរាជរដ្ឋាភិបាល ។

តាមព្រះពុទ្ធសាសនា តុលាការដែលកាត់សេចក្តីមិនយុត្តិធម៌ គឺតុលាការកាត់សេចក្តីដោយអគតិធម៌បួនយ៉ាង ។ អគតិធម៌ ប្រែថាធម៌លំអៀងមានបួនយ៉ាងគឺ ៖ ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់, ទោសាគតិ លំអៀងព្រោះស្អប់, ភយាគតិ លំអៀងព្រោះខ្លាច, មោហាគតិ លំអៀងព្រោះល្ងង់ ។ អគតិធម៌ទាំងបួននេះ ជាអំពើអយុត្តិធម៌ ប្រែថាធម៌ពុំត្រឹមត្រូវ ជាគន្លងនៃអំពើបាប ។ ឆន្ទាគតិ លំអៀងព្រោះស្រឡាញ់ សំរេចសេចក្តីអ្វីមួយដោយការកាន់ជើង កាត់សេចក្តីសំរេចឲ្យអ្នកដែលខ្លួនកាន់ជើងនោះឈ្នះ ព្រោះហេតុតែស្រឡាញ់ ទោះអ្នកនោះមានកំហុសក៏ដោយ ។ ទោសាគតិ លំអៀងព្រោះស្អប់ បើទោះបីអ្នកដែលខ្លួនស្អប់នោះពុំមានកំហុសក៏ដោយ ក៏ឲ្យខុសឲ្យចាញ់ដែរ ព្រោះហេតុតែស្អប់ ។ ភយាគតិ លំអៀងព្រោះភ័យខ្លាច ពុំហ៊ានសំរេចឲ្យខុសដល់អ្នកដែលមានកំហុស ដែលជាអ្នកមានអំណាចបុណ្យស័ក្តិ មានទ្រព្យសម្បត្តិច្រើន ដោយខ្លាចអ្នកនោះធ្វើសេចក្តីអន្តរាយដល់ខ្លួន នេះលំអៀងព្រោះភ័យខ្លាច ។ មោហាគតិ លំអៀងព្រោះល្ងង់ ឬពុំដឹងការពិត គឺអ្នកពុំមានវិជ្ជា មានបញ្ញាទន់ខ្សោយ ឬពុំមានសមត្ថភាព គឺកាត់សេចក្តីទៅតាមភាពល្ងង់ខ្លៅរបស់ខ្លួន ។ អគតិធម៌ទាំងបួននេះ ជាធម៌អកុសល ជាអំពើបាប ដែលលោកអ្នកសប្បុរសតែងវៀរចាកពុំប្រព្រឹត្តធ្វើ លោកតែងប្រព្រឹត្តតាមគតិធម៌ គឺភាពត្រឹមត្រូវ ។ ចៅក្រមកាត់សេចក្តីក្នុងតុលាការត្រូវវៀរចាកអគតិធម៌ទាំងបួននេះ ទើបកាត់សេចក្តីមានយុត្តិធម៌ ។

ចំពោះតុលាការក្នុងប្រទេសដែលកាន់របបប្រជាធិបតេយ្យ មានអំណាចឯករាជ្យដាច់ចេញពីអំណាចនីតិបញ្ញត្តិនិងនីតិប្រតិបត្តិ គឺរដ្ឋាភិបាល ។ បានសេចក្តីថា រដ្ឋាភិបាលមាននាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីទី១ជាដើម មិនអាចបញ្ជាតុលាការឲ្យធ្វើតាមខ្លួនបានឡើយ ។ សូម្បីប្រធានាធិបតីឬប្រមុខរដ្ឋក៏ពុំអាចដូច្នោះបានដែរ ។ ផ្ទុយទៅវិញ បើរដ្ឋមន្ត្រីណាប្រព្រឹត្តខុសច្បាប់របស់រដ្ឋ តុលាការមានអំណាចជំនុំជំរះកាត់ទោសរដ្ឋមន្ត្រីនោះដូចជាមនុស្សធម្មតាដែរ គឺមនុស្សគ្រប់រូបទាំងប្រជាពលរដ្ឋទាំងអ្នករាជការ ត្រូវស្ថិតនៅក្រោមអំណាចច្បាប់រដ្ឋដូចគ្នា ។ បើតុលាការមិនឯករាជ្យ ស្ថិតនៅក្រោមអំណាចរដ្ឋាភិបាល តុលាការពុំអាចកាត់ទោសសមាជិករដ្ឋាភិបាលដែលប្រព្រឹត្តខុសបានឡើយ ។

ទាក់ទងនឹងបញ្ហាដីធ្លី មុននឹងរាជរដ្ឋាភិបាលធ្វើសម្បទានឲ្យដល់ក្រុមហ៊ុនណាមួយ ជាការចាំបាច់ត្រូវចរចាជាមួយម្ចាស់ដីឲ្យសុខចិត្តជាមុន បើដីនោះប៉ះពាល់ដល់កម្មសិទ្ធិឯកជន ដើម្បីជៀសវាងការវិវាទដែលត្រូវចោទថា អ្នកមានអំណាចរំលោភយកដីប្រជាពលរដ្ឋ ។ ប្រទេសនៅអឺរ៉ុប បើរដ្ឋត្រូវការទីកន្លែងដែលប៉ះពាល់ដល់ដីឯកជន រដ្ឋបានឲ្យតម្លៃលើសពីទីផ្សារទៅទៀត ។ បើខ្មែរធ្វើបានដូច្នេះ ពិតជាពុំមានបញ្ហាអំពីរឿងដីធ្លីឡើយ ហើយមិនឡើងតុលាការដែលកាត់សេចក្តីដោយអយុត្តិធម៌ដែរ ។ មួយទៀត គណបក្សប្រឆាំងមានសិទ្ធិឲ្យយោបល់ដល់គណបក្សកាន់អំណាច គួរតែយកយោបល់នោះមកពិចារណា មិនគប្បីប្តឹងឡើងតុលាការ ដែលជាតុលាការពុំឯករាជ្យឡើយ ។៚

*